# ៤. រឿងនក្ខត្តឫក្សរបស់ជនពាល

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនក្ខត្តឫក្សរបស់ជនពាល ត្រាស់ព្រះធម្មទេសនានេះថា "បមាទមនុយុញ្ជន្តិ" ដូច្នេះជាដើម ។

សេចក្តីពិស្តារថា បានស្តាប់មក ក្នុងសម័យមួយ គេវាយគងប្រកាសនក្ខត្តឫក្សរបស់ជនពាលក្នុងនគរសាវត្ថី ។ ក្នុងនក្ខត្តឫក្សនោះ ពួកជនពាលដែលអប្បឥតបញ្ញា យកផេះ និងអាចម៍គោលាបរាងកាយ ដើរពោលវាចារបស់ជនអសប្បុរសរហូតអស់ ៧ ថ្ងៃ ឃើញនរណាៗ ជាញាតិក៏ដោយ ជាសម្លាញ់ក៏ដោយ ជាបព្វជិតក៏ដោយ ឈ្មោះថា មានទូវសេចក្តីអៀនខ្មាសមិនមាន ឈរពោលវាចារបស់អសប្បុរសទៀបទ្វារផ្ទះអ្នកស្រុក ។ មនុស្សទាំងឡាយ មិនអាចស្តាប់អសប្បុរិសវាទរបស់ពួកជនពាលនោះបាន ទើបបញ្ជូនទ្រព្យទៅឲ្យកន្លះបាទខ្លះ ១ បាទខ្លះ ១ កហាបណៈខ្លះ តាមកម្លាំងរបស់ខ្លួន ពួកជនពាលកាន់យកទ្រព្យដែលបានហើយ ត្រង់ទ្វារនៃផ្ទះរបស់មនុស្សទាំងនោះហើយ ទើបចៀសចេញទៅ ។ ក៏ក្នុងកាលនោះ ក្នុងក្រុងសាវត្ថី មានព្រះអរិយសាវកប្រមាណ ៥ កោដិ ។ ព្រះអរិយសាវកទាំងនោះបញ្ជូនដំណឹងទៅថ្វាយព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមាន-

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.026_att

ព្រះភាគព្រមទាំងភិក្ខុសង្ឃ ស្តេចកុំចូលទៅកាន់ព្រះនគរ សូមប្រថាប់នៅតែក្នុងព្រះវិហារអស់ ៧ ថ្ងៃ" ក៏ក្នុងកាល ៧ ថ្ងៃនោះ លោកទាំងនោះបានចាត់ចែងយាគូ និងភត្តជាដើម បញ្ជូនទៅកាន់វិហារដើម្បីភិក្ខុសង្ឃ សូម្បីខ្លួនឯងក៏មិនចេញអំពីផ្ទះដែរ ។ ក៏ក្នុងកាលពាលនក្ខត្តឫក្សចប់ហើយ ក្នុងថ្ងៃទី ៨ អរិយសាវកទាំងនោះ និមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធាន យាងស្តេចចូលទៅកាន់ព្រះនគរថ្វាយមហាទាន អង្គុយក្នុងទីដ៏សមគួរមួយ ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ៧ ថ្ងៃរបស់ពួកខ្ញុំព្រះអង្គកន្លងទៅបានដោយលំបាកណាស់ កាលពួកខ្ញុំព្រះអង្គ បានឮនូវវាចាមិនមែនរបស់សប្បុរសនៃពួកជនពាល ត្រចៀកទាំង ២ ហាក់ដូចជាដល់នូវអាការបែកធ្លាយ នរណាៗ ក៏មិនមានសេចក្តីអៀនខ្មាសនឹងនរណាៗ ព្រោះហេតុនោះពួកខ្ញុំព្រះអង្គ ទើបមិនយាងព្រះអង្គស្តេចចូលកាន់ព្រះនគរ សូម្បីពួកខ្ញុំព្រះអង្គ ក៏មិនអាចចេញអំពីផ្ទះបានដែរ ។ ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវពាក្យរបស់អរិយសាវកទាំងនោះហើយ ត្រាស់ថា "កិរិយារបស់ពួកបុគ្គលដែលអប្បឥតបញ្ញា រមែងដូច្នេះឯង ចំណែកបុគ្គលអ្នកមានបញ្ញាទាំងឡាយរក្សានូវសេចក្តីមិនប្រមាទទុក ដូចជាទ្រព្យដ៏មានខ្លឹមសារ រមែងសម្រេចនូវ

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.026_att

សម្បត្តិ គឺ អមតមហានិព្វាន ដូច្នេះ ទើបទ្រង់បានត្រាស់ព្រះគាថាទាំងនេះ ថា ៖

ប មា ទ ម នុ យុ ញ្ជ ន្តិ ពាលា ទុម្មេធិនោ ជនា
អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ។
មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ
អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ ។

ពួកជនពាលអបឥតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្ដីប្រមាទ ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុកនូវសេចក្ដីមិនប្រមាទដូចទ្រព្យដ៏ប្រសើរ ។ អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗនូវសេចក្ដីប្រមាទ ចូរកុំប្រកបរឿយៗនូវសេចក្ដីរីករាយ ត្រេកអរក្នុងកាមឡើយ ត្បិតបុគ្គលមិនប្រមាទ ទំសង្កេតពិនិត្យ រមែងបាននូវសេចក្ដីសុខដ៏ទូលាយ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ពាលា (ពួកជនពាល) បានដល់ អ្នកប្រកបដោយភាពជាជនពាល គឺ អ្នកដែលមិនស្គាល់ប្រយោជន៍ក្នុងលោកនេះ

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.026_att

និងលោកខាងមុខ ។

បទថា ទុម្មេធិនោ (អ្នកមានបញ្ញាថោកទាប) គឺ ឥតបញ្ញា ។ ពួកជនពាលនោះ កាលមិនឃើញទោសក្នុងសេចក្ដីប្រមាទ រមែងប្រកបរឿយៗនូវសេចក្ដីប្រមាទ គឺ រមែងញ៉ាំងកាលឲ្យកន្លងទៅដោយសេចក្ដីប្រមាទ ។

បទថា មេធាវី (អ្នកមានបញ្ញា) ជាដើម សេចក្ដីថា ចំណែកបណ្ឌិតដែលប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ រមែងរក្សាទុកនូវសេចក្ដីមិនប្រមាទ ដូចទ្រព្យ គឺ រតនៈ ៧ ប្រការដ៏ប្រសើរ គឺ ដ៏ខ្ពង់ខ្ពស់ ដែលជាប់តមកអំពីវង្សត្រកូល អធិប្បាយថា ដូចជនទាំងឡាយ កាលឃើញអានិសង្សក្នុងទ្រព្យថា "យើងទាំងឡាយអាស្រ័យទ្រព្យដ៏ខ្ពង់ខ្ពស់ ទើបដល់នូវសម្បត្តិ គឺ កាមគុណ ទើបធ្វើផ្លូវជាទីទៅកាន់បរលោកឲ្យបរិសុទ្ធបាន" រមែងរក្សាទ្រព្យនោះទុក យ៉ាងណាមិញ សូម្បីបណ្ឌិតក៏ដូច្នោះ កាលឃើញអានិសង្សនៃសេចក្ដីមិនប្រមាទថា "បុគ្គលអ្នកមិនប្រមាទហើយ រមែងបានចំពោះនូវឈានទាំងឡាយ មានបឋមឈានជាដើម រមែងសម្រេចលោកុត្តរធម៌ មានមគ្គ និងផលជាដើម រមែងញ៉ាំងវិជ្ជា ៣ (និង) អភិញ្ញា ៦[១] ឲ្យដល់ព្រមបាន" រមែងរក្សា

១ ឥទ្ធិវិធី សម្ដែងឫទ្ធិបាន, ទិព្វសោត ត្រចៀកទិព្វ, ចេតោបរិយញ្ញាណ កំណត់ដឹងចិត្តអ្នកដទៃ, បុព្វេនិវាសានុស្សតិ រឭកជាតិបាន, ទិព្វចក្ខុ ភ្នែកទិព្វ, អាសវក្ខយញ្ញាណ ញាណធ្វើអាសវៈឲ្យអស់ទៅ, រួមជាអភិញ្ញា ៦ ។ ៣ ខាងចុង ហៅថា វិជ្ជា ៣ ក៏បាន ។

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.026_att

សេចក្ដីមិនប្រមាទទុក ដូចជារក្សាទ្រព្យដ៏ប្រសើរ ។ បទថា មា បមាទំ (កុំតាមប្រកប) សេចក្ដីប្រមាទ សេចក្ដីថា ព្រោះហេតុនោះ អ្នកទាំងឡាយចូរកុំតាមប្រកបរឿយៗ នូវសេចក្ដីប្រមាទ គឺ កុំញុំាងកាលវេលាឲ្យកន្លងទៅដោយសេចក្ដីប្រមាទ ។ បទថា មា កាមរតិសន្ថវំ (កុំតាមប្រកបសេចក្ដីស្និទ្ធស្នាលដោយសេចក្ដីត្រេកអរក្នុងកាម) សេចក្ដីថា ចូរកុំប្រកប គឺ កុំគិតបានដល់ កុំបានចំពោះសូម្បីនូវសេចក្ដីស្និទ្ធស្នាលដោយអំណាចនៃតណ្ហាពោលគឺ សេចក្ដីត្រេកអរក្នុងវត្ថុកាម និងកិលេសកាម ។ បទថា អប្បមត្តោ ហិ (ព្រោះថាបុគ្គលមិនប្រមាទហើយ) ជាដើម សេចក្ដីថា ព្រោះថាបុគ្គលអ្នកមិនប្រមាទហើយ ដោយភាពជាអ្នកមានសតិតាំងមាំ ខំសង្កេតពិនិត្យ រមែងសម្រេចនិព្វានសុខដ៏ទូលំទូលាយ គឺ ដ៏ឧឡារ ។

ក្នុងកាលចប់គាថា ជនជាច្រើនបានជាអរិយបុគ្គល មានសោតាបន្នជាដើម ធម្មទេសនាបានជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

ចប់ រឿងនក្ខត្តឫក្សរបស់ជនពាល

www.sangham.net/km/atthakatha/sut/kn/dhp/sut.kn.dhp.026_att